**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជំរាបជូន**

**ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានី និងគ្រប់ខេត្ត ក្នុងព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុៈ** អំពីការចូលរួមប្រជុំបន្តផ្ទាល់ តាមរយៈការបញ្ជូនរូបភាព និងសម្លេង ( **Video Conference** ) នៅក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ។

**យោងៈ** មតិណែនាំដ៏ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណា ចក្រកម្ពុជា ក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី ០៤ ខែធ្នូ ឆ្នាំ២០០៩

តបតាមកម្មវត្ថុ និងយោងដូចមានចែងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រី សូមជម្រាបជូន **ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី និងគ្រប់ខេត្ត** មេត្តាជ្រាបថាៈ កន្លងមករាជរដ្ឋាភិបាលបានបំពាក់ឧបករណ៍បញ្ជូនរូបភាពដែលអាចដំណើរការប្រជុំបន្តផ្ទាល់ពី គ្រប់ខេត្ត-រាជធានីរួចរាល់ហើយ ទន្ទឹមនឹងនេះដើម្បីបង្កើនប្រសិទ្ធភាព ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីប្រចាំសប្តាហ៍ និងអាចដំណើរការបានដោយរលូនក្នុងការចូលរួមផ្តល់របាយការណ៍ក៏ដូចជាបញ្ហាបន្ទាន់ផ្សេងៗចំពោះប្រមុខរាជរដ្ឋាភិបាលបានទាន់ពេលវេលាផងនោះ ទីស្តីការគណៈរដ្ឋមន្ត្រី សូមស្នើ **ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានី និងគ្រប់ខេត្ត** ចូលរួមក្នុងសម័យប្រជុំពេញអង្គ គណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍ តាមរយៈកញ្ចក់វីដេអូ ( **Video Conference** ) នៅរៀងរាល់ **ថ្ងៃសុក្រ ចាប់ពីម៉ោង ៨:៣០នាទីព្រឹក** ទៅ។

អាស្រ័យដូចបានជម្រាបខាងលើ សូមឯកឧត្តម មេត្តាជ្រាប និងមានវិធានការអនុវត្ត ក្នុងស្មារតីទទួលខុសត្រូវខ្ពស់បំផុត ។

សូមឯកឧត្តមទទួលនូវសេចក្តីស្រលាញ់រាប់អានដ៏ស្មោះអំពីខ្ញុំ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៩

**ឧបនាយរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**